## រដ្ឋឡូសអេនជីលេស )
## នាយកដ្ឋានសុខភាពផ្លូវចិត្ត

# សេចក្តីថ្លែងការណ៍បេសកកម្ម

លើកកំពស់ជីវិតរស់នៅតាមរយៈដៃគូ ក្នុងទិស-ដៅពង្រឹងសមត្ថភាព សហគមន៍

## តើស្ថានការណ៍អាសន្ននៃជំងឺបូសអង់ត្រាក់គឺជាអ្វី ?

ជំងឺបូសអង់ត្រាក់គឺជាជំងឺឆ្លងធ្ងន់ធ្ងរមួយដែលបណ្តាលដោយលំអងមេរោគបាក់តេរី Bacillus anthracis ។ វាកើតមានជាទូទៅនៅលើសត្វព្រៃនិងសត្វស្រុក (គោក្របី ចៀម ពពែ អូដ្ឋ ថនិកសត្វម្យ៉ាងស្រដៀងសត្វឈ្លូស និង សត្វស៊ីស្មៅផ្សេងៗទៀត) ប៉ុន្តែ វាក៏អាចកើតមានលើមនុស្ស នៅ-

## តើការប៉ះពាល់អាចកើតឡើងដោយរបៀបណា?

ពលដែលពួកគេប៉ះពាល់ជាមួយសត្វ ដែលឆ្លងជំងឺ ។

**ការប៉ះពាល់បូសអង់ត្រាក់ពីសត្វពាហនៈ**

មនុស្សអាចឆ្លងបូសអង់ត្រាក់ដោយការប៉ះពាល់ជាមួយនឹងផលិតផលនៃសត្វពាហនៈដែលមានជំងឺ ឬ ដោយការដកដង្ហើមចូលនូវលំអងមេរោគនៃបូសអង់ត្រាក់ពីផលិតផលសត្វដែល មានជំងឺ (ដូចរោមចៀម ជាឧទាហរណ៍) ។ មនុស្សក៏អាចឆ្លង បូសអង់ត្រាក់តាមផ្លូវចំណីអាហារ (ក្រពះពោះវៀន) ដោយការហូបសាច់សត្វដែលមានជំងឺដោយ មិនបានចំអិនឱ្យឆ្អិន។

**បូសអង់ត្រាក់ ដែលជាអាវុធ**

មេរោគបូសអង់ត្រាក់ដែលមានទំរង់ជាម្សៅ អាចត្រូវបានគេ ព្រ-



## តើអ្នកបានប៉ះពាល់ដែរឬទេ?

**រោគសញ្ញានៃបូសអង់ត្រាក់ ប្រែប្រួលអាស្រ័យលើប្រភេទនៃការឆ្លង ។**

**បូសអង់ត្រាក់អាចរាតត្បាតតាមវិធី 3 យ៉ាង**

**ស្បែក-*ស្បែក***

រោគសញ្ញាដំបូងគឺមានដំបៅតូចមួយដែលក្លាយជាពងបែក ជាធម្មតាមានវិជ្ជមាត្រ 1-3 សង់ទីម៉ែត្រ ។ បន្ទាប់មកពងបែកវិវឌ្ឍន៍ទៅជាដំបៅលើស្បែកដែលមានផ្ទៃខ្មៅនៅ ចំកណ្តាល។ ដំបៅ ពងបែក និង ដំបៅរលួយ មិនធ្វើឱ្យឈឺចាប់ឡើយ

**ការដកដង្ហើមចូល — *សួត***

រោគសញ្ញាដំបូងនៃការដកដង្ហើមចូលនូវបូសអង់ត្រាក់ គឺដូចជាការផ្តាសាយធម្មតា ។ ច្រើនថ្ងៃបន្ទាប់មក រោគសញ្ញាវិវឌ្ឍន៍ទៅរកបញ្ហាពិបាកដកដង្ហើមធ្ងន់ធ្ងរ និងស្ទុក ។ ជំងឺបូសអង់ត្រាក់ជាទូទៅគឺអាចបណ្តាលឱ្យស្លាប់ ប្រសិ-នបើបានដកដង្ហើមចូល និង មិនទទួលបានការព្យាបាលជាមួយនឹងថ្នាំផ្សះភ្លាមៗទេ

**ផ្លូវចំណីអាហារ -*ក្រពះពោះវៀន***

បន្ទាប់ពីបានហូបសាច់ដែលមានមេរោគ អ្នកអាចមានរោគសញ្ញាចង្អោ មិន-ឃ្លានបាយ ក្អួត ក្តៅខ្លួនដោយមានឈឺពោះ ក្អួតចេញឈាម និងរាគរូសខ្លាំង ។ រោគសញ្ញាក៏អាចមានដំបៅនិងឈឺបំពង់ក ពិបាកលេប ឃើញមានហើមក និង ហើមក្រពេញ ។

## កាត់បន្ថយការប៉ះពាល់

**ការបង្ការ**

***ការបង្ការក្រោយពេលប៉ះពាល់*** ការព្យាលបាលគឺខុសគ្នាចំពោះមនុស្សដែលប៉ះពាល់ជាមួយនឹងបូសអង់ត្រាក់ ប៉ុន្តែមិនទាន់ធ្លាក់ខ្លួនឈឺនៅឡើយ ។ អ្នកផ្តល់សេវាថែទាំសុខភាព នឹងប្រើប្រាស់ថ្នាំផ្សះ (ដូចជាស៊ីប្រូហ្លូសាស៊ីន [ciprofloxacin] លីវូហ្លូសាស៊ីន [levofloxacin] ដុកស៊ីស៊ីខ្លីន [doxycycline] ឬ ប៉េនីស៊ីលីន [penicillin]) ជាមួយនឹងការចាក់ថ្នាំវ៉ាក់សាំងការពារបូសអង់ត្រាក់ ដើម្បីបង្ការការឆ្លងនៃជំងឺបូសអង់ត្រាក់ ។

**ការព្យាបាល**

***ការព្យាលក្រោយពេលឆ្លងជំងឺ*** ការព្យាបាលដោយថ្នាំផ្សះជាទូទៅមានរយៈពេល 60ថ្ងៃ។ ភាពជោគជ័យអាស្រយ័ប្រភេទនៃបូសអង់ត្រាក់ និង ភាព-ឆាប់រហ័សនៃការចាប់ផ្តើម ព្យាលបាល ។

***ការចាក់វ៉ាក់សាំងការពារ*** មានថ្នាំវ៉ាក់សាំងដើម្បីការពារបូសអង់ត្រាក់ ប៉ុន្តែ មិន-ទាន់អាចរកបានសម្រាប់ប្រជាជនទូទៅនៅឡើយទេ ។ អ្នកណាម្នាក់ដែលអាចប៉ះពាល់ជាមួយបូសអង់ត្រាក់ ដោយរួមទាំងសមាជិកនៃកងកម្លាំងការងាររបស់សហរដ្ឋអាមេរិច អ្នកធ្វើការនៅមន្ទីរពិសោធន៍ និង

## ប្រតិកម្ម

**ប្រតិកម្មដែលមានជាធម្មតា**

- ការភ័យខ្លាចចំពោះភ្នាក់ងារបង្ករោគដែលមិនអាចមើលឃើញ ឬ ការចម្លងរោគ
- កំហឹងចំពោះឧក្រិដ្ឋជន ឬ រាជរដ្ឋាភិបាល
- បាត់បង់ជំនឿចំពោះស្ថាបន័
- ការនៅដាច់ឯកកោពីសង្គម ឬ ការដកថយ
- ព្រួយបារម្ភណ៍ខ្លាំង
- គ្មានសង្ឃឹម និង សោកសៅ
- រំខានដល់ការសម្រាន្ត
- ភ័យខ្លាចចំពោះការស្លាប់ដោយការឆ្លងជំងឺ

**ផលប៉ះពាល់ក្នុងរយៈពេលយូរ**

ប្រសិនបើអ្នក ឬ មនុស្សជាទីស្រលាញ់របស់អ្នក ពិបាកដោះស្រាយបញ្ហាក្នុង កំឡុងពេលនេះ អ្នកត្រូវស្វែងរកអ្នកឯកទេសដើម្បីព្យាបាលបញ្ហា។

**ភាពងាយត្រលប់មករកភាពដើមវិញ**

មនុស្សភាគច្រើននឹងរកបានវិធីដោះស្រាយនឹងការប៉ះទង្គិច ផ្លូវចិត្តនេះ។ ជាញឹកញាប់ បានអនុវត្តដូចតទៅ

- យល់ដឹងថា ប្រតិកម្មរបស់អ្នកជាប្រតិកម្មធម្មតា
- រក្សាសកម្មភាពជាប្រចាំ
- រកវិធីដើម្បីលំហែរចិត្ត និងគិតពីខ្លួនឯង
- ចូលរួមក្នុងសកម្មភាពផ្សេងៗដែលអ្នកចូលចិត្ត
- កត់សំគាល់ថាអ្នកមិនអាចត្រួតពិនិត្យបានគ្រប់បែបយ៉ាងនោះទេ
- ពិភាក្សាជាមួយអ្នកដែលមានបញ្ហាស្រដៀងគ្នា ដែលសង្ឃឹមថានឹងទទួល បានបទពិសោធន៍របស់ជននោ
- ត្រលប់មករកក្រុមគ្រួសារ មិត្តភ័ក្ត បព្វជិត ឬ អ្នកណាម្នាក់ដែលអ្នកជឿ ជាក់ សំរាប់ការគាំទ្រ
- ទទួលស្គាល់ នៅពេលដែលអ្នកត្រូវការរកជំនួយឯកទេស

## ចំនុចសំខាន់ៗសំរាប់ដោះស្រាយបញ្ហា

**អ្វីដែលអាចធ្វើបានដើម្បីកូនរបស់អ្នក និងក្មេងជំទង់**

- ស្មោះត្រង់ និងផ្តល់មូលហេតុដែលស័ក្តិសមនឹងអាយុស្តីពីព្រឹត្តការណ៍ដែលប៉ះទង្គិចផ្លូវចិត្ត
- ជួយកុមារឱ្យបង្ហាញពីអារម្មណ៍របស់ខ្លួន
- ត្រូវស្តាប់ជានិច្ច នូវការនិយាយអំពីបទពិសោធន៍របស់ពួកគេ
- ផ្តល់ការណែនាំពីសកម្មភាពប្រចាំថ្ងៃរបស់ពួកគេនិងរក្សាទំលាប់
- ផ្តល់ឱ្យពួកគេនូវឯកសារវិចិត្រសិល្បៈ ដូចជាការគូរគំនូរ ដើម្បីបញ្ចេញអារម្មណ៍របស់ពួកគេ
- កំណត់ព្រំដែនព័ត៌មាន

**យុទ្ធសាស្ត្រដោះស្រាយបញ្ហាចំពោះមនុស្សចាស់**

- និយាយពីអារម្មណ៍របស់អ្នក
- ចែករំលែកបទពិសោធន៍ជាមួយជនរងគ្រោះមហន្តរាយ អាចជួយដល់ដំណើរការត្រលប់ទៅរកភាពដើមវិញ
- រក្សាការទំនាក់ទំនងជាប្រចាំ ជាមួយនឹងមិត្តភ័ក្ត និងក្រុមគ្រួសារ
- ត្រូវចងចាំថាប្រតិកម្មខាងរាង្គកាយ និងផ្លូវចិត្តចំពោះគ្រោះមហន្តរាយ គឺជារឿងធម្មតា
- មិនត្រូវមើលទូរទស្សន៍ច្រើនពេក
- ចូលរួមនៅក្នុងដំណើរការជាសះស្បើយនៃគ្រោះមហន្តរាយ ការដែលអាចជួយនរណាម្នាក់ឱ្យបានជាសះស្បើយអាចមានផលប្រយោជន៍ចំពោះការសះស្បើយរបស់ខ្លួនឯង
- ស្តាប់ការណែនាំតាមវិទ្យុ និង ទូរទស្សន៍

## រក្សាការតាមដានស្តាប់នូវព័ត៌មាន

- ត្រូវរក្សាការតាមដានស្តាប់ព័ត៌មាន។ ស្តាប់សេចក្តីរាយការណ៍ និង-ការណែនាំ ជាផ្លូវការតាមរយៈវិទ្យុ ឬ ទូរទស្សន៍
- ប្រសិនបើមានបញ្ហាជាផ្លូវការអោយធ្វើការជម្លៀសចេញ នោះត្រូវផ្តល់កិច្ច សហប្រតិបត្តិការយ៉ាងរូសរាន់ និងអនុវត្តតាមការណែ-នាំរបស់ពួកគេ ទាក់ទង ទៅនឹងផ្លូវដែលត្រូវជម្លៀសទៅ និង-ទីកន្លែងដែលត្រូវទៅតាំងទីលំនៅ។
- អ្នកអាចនឹងត្រូវបានណែនាំអោយ "ស្នាក់នៅនឹងកន្លែង" ដែល-មានន័យថា អ្នកត្រូវស្នាក់នៅក្នុងផ្ទះ ឬ ការិយាល័យរបស់អ្នក ឬ អ្នកអាចត្រូវបានណែនាំ អោយរើទៅកាន់កន្លែងផ្សេងទៀត។
- មិនត្រូវចាកចេញពីទីលំនៅរបស់អ្នកទេ ដ៏រាបណាមានការណែនាំពីអាជ្ញាធរ។

## ការរៀបចំកញ្ចប់សង្គ្រោះបន្ទាន់

**ប្រសិនបើអ្នកមានសមាជិកគ្រួសារ ឬ មិត្តភ័ក្តណាម្នាក់ដែលមានតំរូវ ការជាក់លាក់ អ្នកត្រូវរៀបចំជា-មុនដើម្បីឆ្លើយតបទៅនឹងតំរូវការ ទាំងអស់នោះ។ ការ-រៀបចំកញ្ចប់សង្គ្រោះបន្ទាន់គឺត្រូវធ្វើដូចតទៅនេះ :**

- ត្រូវមានអាហារដែលអាចរក្សាទុកបានយូរសំរាប់រយ:ពេល ២ សប្តាហ៍ និងប្រដាប់បើកកំប៉ុងដោយដៃផង
- ទឹកស្អាតសំរាប់រយ:ពេល ២ សប្តាហ៍ [1 ហ្គាលូន (3.7 លីត្រ) សំរាប់ ១ នាក់ ក្នុង ១ ថ្ងៃ
- វិទ្យុ ឬ ទូរទស្សន៍ប្រើថ្មរពិលដែលអាចយូរបាន ព្រមទាំងថ្មរពិលបំរុង
- ពិល និងថ្មពិលបំរុង
- សំភារ:សង្គ្រោះបឋម
- សំភារ:អនាម័យ (សាប៊ូលាងដៃ កន្សែង ដែលមានស-ំណើម និងក្រដាសអនាម័យ)
- ឈើគូសក្នុងប្រអប់ដែលមិនជ្រាបទឹក
- កព្ជៀរផ្ចំ សំលៀកបំពាក់សំរាប់ផ្លាស់ប្តូរ និងភួយដណ្តប់
- វ៉ែនតា កែវពាក់ក្នុងភ្នែក និងទឹកថ្នាំដាក់ភ្នែក
- សំភារ:សំរាប់ទារក ដូចជា ទឹកដោះគោ ខោទឹកនោម ដបទឹកដោះគោ ក្បាលដោះសិប្បនិម្មិត ។
- សំភារ:ជាង សំភារ:សំរាប់សត្វជាដើម ផែនទីក្នុងតំបន់

**ការពិចារណាពិសេសសម្រាប់ជនពិការ :**

- រៀបចំកញ្ចប់/ផែនការសង្គ្រោះបន្ទាន់ ជាក់លាក់ទៅតាមតំរូវការជាក់ស្តែងរបស់អ្នក
- វ៉ែនតា ថ្មរពិល ឧបករណ៍ជំនួយការស្តាប់ និងសំភារ:ចល័តបន្ថែមទៀត ក្នុងករណីដែលសំភារ:ខូច
- រៀបចំបញ្ជីសំភារ:ពិសេសដែលអ្នកប្រើ និងសេចក្តីណែនាំ ប្រសិនបើអ្នកមានបញ្ហាក្នុងការទំនាក់ទំនង
- រៀបចំបញ្ជីទាក់ទងដែលលំអិតសំរាប់ស្ថានភាពអាសន្ន ដែលមានបញ្ចូលទាំងគ្រួសារ មិត្តភ័ក្ត និងវេជ្ជបណ្ឌិត

## ប្រភពធនធាន

**រដ្ឋឡូសអេនជីលេស**

**នាយកដ្ឋានសុខភាពផ្លូវចិត្ត**

**មជ្ឈមណ្ឌលទូរស័ព្ទទាន់ហេតុការណ៍**

**លេខ:** 1-800 854-7771 **ឬ**

**លេខ:** 562-651-2549 TDD/TTY

(បំរើការ24 ម៉ោងក្នុង 1 ថ្ងៃ 7 ថ្ងៃក្នុង 1 សប្តាហ៍ រាប់ទាំងថ្ងៃឈប់សំរាក)

**រដ្ឋឡូសអេនជីលេស**

**នាយកដ្ឋានសុខភាពសាធារណ:**

1-800-427-8700 **ឬ** ph.lacounty.gov

**រដ្ឋឡូសអេនជីលេស**

**សេវាកម្មជនជរា និង សហគមន៍**

213-738-2600 **ឬ** dcss.co.la.ca.us

**ក្រុងឡូសអេនជីលេស នាយកដ្ឋានជនពិការ**

213-202-2764 **ឬ** 213-202-2755 TTY

**ឬ** lacity.org/dod

**រដ្ឋឡូសអេនជីលេស**

**នាយកដ្ឋានថែទាំ និងត្រួតពិនិត្យសត្វពាហន:**

562-728-4882 **ឬ** animalcare.lacounty.gov

**ខ្សែទូរស័ព្ទព័ត៌មានរដ្ឋឡូសអេនជីលេស**

**ទូរស័ព្ទមកលេខ:** 211 **ឬ** 211la.org

**ខ្សែទូរស័ព្ទព័ត៌មានក្រុងឡូសអេនជីលេស ទូរស័ព្ទមកលេខ:**

311 **ឬ** lacity.org/LAFD/311.htm

## រដ្ឋឡូសអេនជីលេស

## គណៈកម្មការនាយក

**Gloria Molina**

តំបន់ទី ១ (First District)

**Mark Ridley-Thomas**

តំបន់ទី ២ (Second District)

**Zev Yaroslavsky**

តំបន់ទី ៣ (Third District)

**Don Knabe**

តំបន់ទី ៤ (Fourth District)

**Michael D. Antonovich**

តំបន់ទី ៥ (Fifth District)

**William T Fujioka**

មន្ត្រីនាយកប្រតិបត្តិ CEO

**រដ្ឋឡូសអេនជីលេស**

**នាយកដ្ឋានសុខភាពផ្លូវចិត្ត**

**ការិយាល័យទំនាក់ទំនងរដ្ឋាភិបាល និងសហគមន៍**

**មន្ត្រីព័ត៌មានសាធារណ:**

KHM

550 South Vermont Avenue, 6th Floor
Los Angeles, CA 90020
213-738-3700
**dmh.lacounty.gov**

## រដ្ឋឡូសអេនជីលេស

## នាយដ្ឋានសុខភាពផ្លូវចិត្ត



## ស្ថានការណ៍អាសន្ននៃជំងឺឬសអង់ត្រាក់

*កសាងក្តីសង្ឃឹម លើកកំពស់សុខុមាលភាព និង គាំទ្រការរស់រានមានជីវិតឡើងវិញ*

**ការិយាល័យសង្គ្រោះបន្ទាន់តាមមូលដ្ឋាន**

**សេវាកម្មពេលមានគ្រោះមហន្តរាយ**

550 South Vermont Avenue, 10th Floor
Los Angeles, CA 90020
213-738-4919
dmh.lacounty.gov

**លោក Marvin J. Southard, DSW**
**នាយក**